# របាយការណ៍សង្ខេប
# ស្តីពី
# "វឌ្ឍនភាព និង ទិសដៅការងារបន្តរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់"
# ក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការគណៈរដ្ឋមន្ត្រី
# ឯកឧត្តម អ៊ាន យុន ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប

(ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១)

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សូមគោរព សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ***ជាទីគោរព!***
- សូមគោរព **ឯកឧត្តម ប៉ៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ***ជាទីគោរព!***
- លោក លោកស្រី បងប្អូនអ្នកសារព័ត៌មាន និង បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់ ***ជាទីគោរពស្រលាញ់រាប់អាន!***

ថ្ងៃនេះ ជួសមុខឱ្យក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ ប្រជាពលរដ្ឋទូទាំងខេត្ត និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ពិតជាមានក្តីសោមនស្សរីករាយក្រៃលែងដោយបានចូលរួមជាវាគ្មិនកិត្តិយសក្នុងសន្និសីទសារព័ត៌មាន ស្តីពី "វឌ្ឍនភាព និង ទិសដៅការងារបន្តរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់" នាពេលនេះ។ មុននឹងធ្វើសេចក្តីរាយការណ៍អំពីវឌ្ឍនភាពការងារឆ្នាំ២០២០ និង ទិសដៅការងារឆ្នាំ២០២១ របស់រដ្ឋបាលខេត្ត ក្នុងនាមរដ្ឋបាលខេត្ត និង ប្រជាពលរដ្ឋទូទាំងខេត្ត សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការស្វែងរកនូវសន្តិភាពជូនជាតិមាតុភូមិ និង ការអភិវឌ្ឍជាបន្តបន្ទាប់ និងនិយាយដោយឡែកសម្រាប់ខេត្តសៀមរាបផងដែរ។ ស្ថិតក្នុងប្រធានបទ នៃការធ្វើសន្និសីទសារព័ត៌មាននៅពេលនេះ ខ្ញុំបាទនឹងធ្វើសេចក្តីរាយការណ៍ជូនសាធារណជន និង អ្នកសារព័ត៌មាននាពេលនេះនូវវឌ្ឍនភាពការងារឆ្នាំ២០២០ និង ទិសដៅការងារឆ្នាំ២០២១ របស់រដ្ឋបាលខេត្ត ដូចខាងក្រោម៖

## I- ស្ថានភាពទូទៅ

- ប្រជាពលរដ្ឋសរុបចំនួន ១ ១៣៧ ៦៧៦នាក់ ស្រី ៥៧៦ ៤៧៨នាក់ គិតជាគ្រួសារ ស្មើនឹង ២៤៥ ៥០៧គ្រួសារ កំណើនប្រជាជន ២.១៧ភាគរយ ដង់ស៊ីតេ ១១០,៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។
- ខេត្តសៀមរាបមានផ្ទៃដីសរុប ១០ ២៩៩,៤៣គីឡូម៉ែត្រការ៉េ ក្នុងនោះផ្ទៃដីកសិកម្មមានទំហំ ២៣៦ ៩០០ហិកតា ដែលមានផ្ទៃដីដំណាំស្រូវ ២០៧ ២០០ហិកតា (ស្រូវវស្សា ១៩៦ ២០០ហិកតា

ស្រូវប្រាំង ២១ ០០០ហិកតា) ដំណាំរួមផ្សំ ២១ ០០០ហិកតា និងដំណាំឈើហូបផ្លែ កសិឧស្សាហកម្ម ៨ ៧០០ហិកតា (មិនទាន់រាប់បញ្ចូលផ្ទៃដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន)។

- ដោយផ្អែកទៅលើសម្បត្តិវប្បធម៌ ទីតាំងភូមិសាស្ត្រ បានធ្វើឱ្យខេត្តសៀមរាបមានសក្តានុពលសេដ្ឋកិច្ចជាចម្បងលើវិស័យកសិកម្ម និង ទេសចរណ៍។
- តាមរយៈសក្តានុពលទាំងនេះ បានធ្វើឱ្យសេដ្ឋកិច្ចខេត្តសៀមរាប ទទួលបាននូវផលិតផលក្នុងស្រុកសរុប (ផសស/GDP) ១ ៦៣៦លានដុល្លារអាមេរិក ជាមួយនឹងប្រាក់ចំណូលជាមធ្យម(ផសស) សម្រាប់មនុស្សម្នាក់ស្មើនឹង ១ ៥៤៥ដុល្លារអាមេរិក។
- សណ្ឋាគារសរុបមាន ២២៨កន្លែង ស្មើនឹង ១៤ ៥៩៩ បន្ទប់ផ្ទះសំណាក់មានចំនួន ៣១០កន្លែង ស្មើនឹង ៤ ៦៧៩បន្ទប់។
- ភោជនីយដ្ឋានសរុបចំនួន ១៩៦កន្លែង ម៉ាស្សា ៥០កន្លែង ខារ៉ាអូខេចំនួន ១៤កន្លែង ឌីស្កូតែកចំនួន ០៤កន្លែង និងកន្លែងវាយកូនហ្គោល ០៣កន្លែង។
- ទីភ្នាក់ងារទេសចរណ៍ ៣២១សាខា មគ្គុទ្ទេសក៍ទេសចរណ៍មានចំនួន ៥ ១៧២នាក់ ស្រី ៧៥៧ នាក់។

## II- **ការងារក្រុមប្រឹក្សាខេត្ត**

- ក្រុមប្រឹក្សាខេត្តបានប្រកាសចូលកាន់មុខតំណែងកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ក្រោមអធិបតីភាព សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តសៀមរាប ក្រុមប្រឹក្សាខេត្តសៀមរាបមានសមាសភាពសរុបចំនួន ២៧រូប ស្រី ០៣រូប ដែលមកពីគណបក្សនយោបាយចំនួន ០២ គឺគណបក្សប្រជាជនកម្ពុជាទទួលបាន ២៦អាសនៈ និងគណបក្សខ្មែររួបរួមជាតិទទួលបាន ០១អាសនៈ។ ក្រុមប្រឹក្សាក្រុង ស្រុកក្នុងខេត្តសៀមរាបមានចំនួនសរុបចំនួន ២១៦នាក់ ស្រី ៣៦នាក់ និងក្រុមប្រឹក្សាឃុំ សង្កាត់ សរុបចំនួន ៦៦៨នាក់ ស្រី ១៤៣នាក់។
- បន្ទាប់ពីប្រកាសចូលកាន់តំណែង ក្រុមប្រឹក្សាខេត្តអាណត្តិទី៣ បានចេញដីកា និងសេចក្តីសម្រេចចំនួន ១៣ ក្នុងនោះ មានដីកាបទបញ្ជាផ្ទៃក្នុង ចំនួន ០១ និងសេចក្តីសម្រេច ចំនួន ១២។ ក្រៅពីនេះក៏បានអនុម័តលើប្រតិទិនកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តទៅតាមឆ្នាំនីមួយៗ បានចំនួន ០២ ហើយបានរៀបចំកិច្ចប្រជុំសាមញ្ញចំនួន ២០លើក វិសាមញ្ញចំនួន ០២លើក និងសម្ងាត់ចំនួន ០៣លើក។ ដោយឡែក ក្នុងឆ្នាំ២០២០ បានអនុវត្ត និង បំពេញតួនាទី ភារកិច្ចរបស់ខ្លួនដោយបានរៀបចំកិច្ចប្រជុំសាមញ្ញ ១២លើក កិច្ចប្រជុំវិសាមញ្ញចំនួន ០១លើក (កិច្ចប្រជុំសម្ងាត់បានចំនួន ១លើក)។
- ក្រុមប្រឹក្សាខេត្តបានដាក់ចេញនូវចក្ខុវិស័យសម្រាប់ការអភិវឌ្ឍនៅក្នុងអាណត្តិទី៣ ដោយបង្កើនប្រសិទ្ធ-ភាព គុណភាព និង តម្លាភាព នៃការផ្តល់សេវាសាធារណៈក្នុងខេត្ត ជំរុញ និង កែលម្អនូវសេវាកម្ម និងផលិតផលនានា ដែលបម្រើឱ្យវិស័យទេសចរណ៍ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក៏ដូចជាលើកកម្ពស់នូវ

សោភ័ណ្ឌភាពក្នុងខេត្តឱ្យស្របតាមសក្តានុពលទេសចរណ៍ដែលខេត្តមានការយកចិត្តទុកដាក់លើក កម្ពស់ជីវភាព និង សុខមាលភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់ សាធារណៈ បរិស្ថាន និង សម្បត្តិវប្បធម៌ប្រពៃណីជាតិ ដែលមានក្នុងខេត្ត។ ដើម្បីសម្រេចបាននូវ ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍនៅក្នុងអាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត រដ្ឋបាលខេត្តមានគោលបំណង អភិវឌ្ឍន៍ចម្បងៗចំនួន ៤ផ្នែក រួមមាន ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ផ្នែកគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

- ក្រោយពីក្រុមប្រឹក្សាខេត្ត បានអនុម័តក្របខណ្ឌអភិវឌ្ឍខេត្ត ផែនការអភិវឌ្ឍប្រាំឆ្នាំ និងផែនការវិនិយោគបីឆ្នាំរំកិល ដែលមានសំណើគម្រោងពីគ្រប់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខេត្ត មន្ទីរ-អង្គភាពជុំវិញខេត្ត ហើយក្នុងនោះ គម្រោងវិនិយោគរបស់រដ្ឋបាលខេត្តសៀមរាប សម្រាប់អនុវត្តក្នុងឆ្នាំ២០២០ សរុបចំនួន ១៩៧គម្រោង ក្នុងនោះគម្រោងមានការសន្យាគាំទ្រដោយរដ្ឋបាលខេត្តសរុបចំនួន ៥២គម្រោង និង គម្រោងមានការគាំទ្រតាមបណ្តាមន្ទីរ-អង្គភាពសរុប ចំនួន ១៤៥គម្រោង។
- ការដោះស្រាយលើសំណួរ-សំណូមពរដែលបានទទួលពីវេទិកាផ្សព្វផ្សាយឆ្នាំ២០១៩ មានចំនួន ៣០៧ ហើយសំណួរ-សំណូមពរ បានដោះស្រាយនិងឆ្លើយបំភ្លឺសរុបបានចំនួន ២១៧សំណួរ-សំណូមពរ នៅសល់ចំនួន ៦៦សំណួរ-សំណូមពរដែលបានដាក់យន្តការឱ្យដោះស្រាយ និងកំពុងដំណើរការដោះស្រាយ។
- ក្រុមប្រឹក្សាខេត្តបានបង្កើតក្រុមការងារចុះគាំទ្រ និង ចូលរួមការងារសម្របសម្រួលក្នុងកិច្ចប្រជុំ និង ចុះដល់តាមបណ្តាក្រុង ស្រុក ឃុំ សង្កាត់ និង មន្ទីរ-អង្គភាព ដើម្បីទទួលបានព័ត៌មាន ផ្តល់យោបល់ និង ដោះស្រាយបញ្ហាប្រឈម ព្រមទាំងជំរុញការអនុវត្តតួនាទី និងភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់និងមន្ទីរ-អង្គភាព បានចំនួន ៤៦៨លើក ។
- លទ្ធផលការងាររបស់គណៈកម្មាធិការ កាតព្វកិច្ចរបស់ក្រុមប្រឹក្សាទាំង ០៣ ទទួលបានដូចខាងក្រោម ៖
  - គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្នុងអាណត្តិទី៣ បានដំណើរការកិច្ចប្រជុំសរុបចំនួន ០៥លើក ដើម្បីពិនិត្យ ពិភាក្សា និងដោះស្រាយសំណួរ-សំណូមពរ និងក្តីកង្វល់របស់ប្រជាពលរដ្ឋ ដែលបានលើកឡើងក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងបញ្ហាផ្សេងៗដែលមន្ទីរ-អង្គភាព និងរដ្ឋបាល ក្រុង ស្រុក បានស្នើលើកឡើងជារបៀបវារៈពិនិត្យពិភាក្សា និងដោះស្រាយ។
  - គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) បានដំណើរការកិច្ចប្រជុំចំនួន ១២លើក ក្រៅពីកិច្ចប្រជុំ គ.ក.ស.ក បានចុះដោះស្រាយបញ្ហាប្រឈមនៅមូលដ្ឋាន ដែលពាក់ព័ន្ធនិងស្ត្រី យុវវ័យ កុមារ និងជនងាយរងគ្រោះ។ ជាមួយគ្នានោះ គ.ក.ស.ក ក៏បានរៀបចំប្រជុំផ្សព្វផ្សាយ ស្តីពីការពង្រឹងតួនាទី ភារកិច្ចរបស់ គ.ក.ស.ក ដល់ គ.ក.ស.ក ក្រុង-ស្រុកទាំង ១២ និង គ.ក.ន.ក ឃុំ សង្កាត់ ជារៀងរាល់ឆ្នាំ និងជំរុញឱ្យមានការចូលរួមពី

សមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងនៅមូលដ្ឋាន។ ក្រៅពីការគាំទ្ររបស់រដ្ឋបាលខេត្ត សកម្មភាពទាំងនេះក៏ទទួលបានការគាំទ្រពីអង្គការដៃគូរផងដែរ។

- គណៈកម្មាធិការលទ្ធកម្មបានដំណើរការកិច្ចប្រជុំចំនួន ០៨លើក ដោយប្រើប្រាស់យន្តការតម្លាភាពលើការដេញថ្លៃរបស់ក្រុមហ៊ុនផ្គត់ផ្គង់ប្រេងឥន្ធនៈ សម្ភារប្រើប្រាស់ និងការអនុវត្តប្រតិបត្តិការចំណាយប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល។

## III-សមិទ្ធផលការងារក្នុងវិស័យចម្បងៗមួយចំនួននាឆ្នាំ២០២០

### ១- វិស័យទេសចរណ៍

- ដោយការរីករាលដាលជំងឺកូវីដ-១៩នៅទូទាំងពិភពលោកក្នុងឆ្នាំ២០២០ បានធ្វើឱ្យភ្ញៀវទេសចរធ្លាក់ចុះយ៉ាងគំហុក ដែលជះឥទ្ធិពលមកលើប្រទេសកម្ពុជា ដោយមានភ្ញៀវទេសចរមកទស្សនាខេត្តសៀមរាបសរុបចំនួន ១ ១០៤ ០៣៦នាក់ មានការថយចុះ ៧៤,០៩ភាគរយ បើប្រៀបធៀបឆ្នាំ២០១៩ ក្នុងនោះមានដូចជា ភ្ញៀវទេសចរអន្តរជាតិមានចំនួនសរុប ៤០០ ៨៨៩នាក់ មានការថយចុះ ៨១,៨២ភាគរយ និងភ្ញៀវទេសចរជាតិមានចំនួនសរុប ៧០៣ ១៤៧នាក់ មានការថយចុះ ៦៥,៨១ភាគរយ ប្រៀបធៀបនឹងឆ្នាំ២០១៩។ ដោយស្ថានភាពជំងឺកូវីដ-១៩ ក្នុងសហគមន៍បានធូរស្រាល បានធ្វើឱ្យទេសចរណ៍ក្នុងស្រុកមានសកម្មភាពមួយចំនួន ជាហេតុធ្វើឱ្យសេវាកម្មទេសចរណ៍ (សណ្ឋាគារ ផ្ទះសំណាក់) អាប់ផាតមិន និងភោជនីយដ្ឋានបានធ្វើឱ្យមានសកម្មភាពមួយចំនួនឡើងវិញតែមិនសូវមានសន្ទុះខ្ពស់នៅឡើយ អាស្រ័យដោយហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងក្រុងជាច្រើនកំពុងដំណើរការសាងសង់។

### ២- វិស័យកសិកម្ម

- បន្ទាប់ពីវិស័យទេសចរណ៍បានធ្លាក់ចុះក្នុងអំឡុងពេលការរីករាលត្បាតជំងឺកូវីដ-១៩ ធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋដែលប្រកបរបរនឹងវិស័យទេសចរណ៍ធ្លាក់ចុះ ហើយប្រជាពលរដ្ឋបានផ្លាស់ប្តូរមុខរបរ ដោយប្រកបរបរកសិកម្មដូចជា ចិញ្ចឹមសត្វ ដាំដំណាំ បន្លែ និងដំណាំរួមផ្សំផ្សេងៗ បានធ្វើឱ្យសកម្មភាព ឬ លទ្ធផលលើការងារកសិកម្មកើនឡើងមុនមានព្រឹត្តការណ៍ជំងឺកូវីដ-១៩។
- វិស័យកសិកម្ម បានបង្កបង្កើនផលស្រូវសរុប ចំនួន ២១៣ ២៨៩ហិកតា នៃផែនការ ដែលការបង្កបង្កើនផលស្រូវរដូវវស្សាបាន ចំនួន ១៩០ ៧០៤ហិកតា ស្មើនឹង ១០២,២២ភាគរយ ដោយទទួលទិន្នផលជាមធ្យម ៣,៥៣០តោនក្នុងមួយហិកតា ស្រូវរដូវប្រាំងលើផ្ទៃដីចំនួន ២២ ៥៨៥ហិកតា និងស្រូវរដូវវស្សាទិន្នផលជាមធ្យម ២,៧៧១តោនក្នុងមួយហិកតា។ ទិន្នផលទទួលបានសរុបទាំងស្រូវប្រាំង និងស្រូវវស្សាចំនួន ៦០៦ ០៦២តោន ហើយការវាយតម្លៃតុល្យភាពស្បៀងឃើញថា ស្រូវលើសតម្រូវការសម្រាប់ការនាំចេញមានចំនួន ២៨៤ ០៧៦តោន។

- រីឯដំណាំរួមផ្សំផ្សេងៗ ដាំដុះបានសរុបចំនួន ៥០ ១៦១ហិកតា ស្មើនឹង ១៣៦,៩ភាគរយ នៃផែនការ ធៀបនឹងឆ្នាំមុនកើនឡើង ១១ ០២១ហិកតា ក្នុងនោះផ្ទៃដីប្រមូលផលបន្លែសរុប ៣ ៨៧៥ហិកតា បានបរិមាណផលចំនួន ៣៥ ១១៩តោន។ ដោយសារវិបត្តិជំងឺកូវីដ-១៩ ភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិថយចុះ និងការកើនឡើងការដាំដុះរបស់ប្រជាកសិករ បានធ្វើឱ្យបរិមាណតម្រូវបន្លែបាន ថយចុះ និងតម្រូវឱ្យនាំចូលពីក្រៅខេត្តមកនៅត្រឹមចន្លោះពី ២០តោន ទៅ ៤០តោនក្នុងមួយខែ។
- ផ្ទៃដីដាំកៅស៊ូ ៨ ៥៣៨ហិកតា ក្នុងនោះក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ចមានចំនួន ៩ក្រុមហ៊ុន អនុវត្តការដាំដុះដំណាំកៅស៊ូលើផ្ទៃដី ៧ ៤៩៩ហិកតា ដោយបានចៀដ័រចំនួន ១ ០៦៦ហិកតា និង ប្រជាពលរដ្ឋដាំដុះជាលក្ខណៈគ្រួសារបានចំនួន ១ ០៣៩ហិកតា ហើយបានចៀដ័រចំនួន ៥៧ហិកតា។
- ចំពោះការងារផលិតកម្មសត្វ ការចិញ្ចឹមសត្វ គោក្របី ជ្រូក មាន់ទា មានចំនួនជាង ៣ លានក្បាល បើធៀបនឹងឆ្នាំ២០១៩ មានការកើនឡើងប្រមាណ ៨,២៨ភាគរយ។

## ៣- វិស័យពាណិជ្ជកម្ម

- ជារួមការងារពាណិជ្ជកម្ម ធ្វើសកម្មភាពលើការងារចុះបញ្ជីពាណិជ្ជកម្ម ការងារគ្រប់គ្រងទីផ្សារ សហការត្រួតពិនិត្យ ជំរុញការងារអភិវឌ្ឍន៍ផលិតផល និងទីផ្សារ សហការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផលទំនិញ និងសេវាកម្មនៅលើទីផ្សារ ព្រមទាំងគាំទ្រសកម្មភាពសភាពាណិជ្ជកម្ម។
- ដោយឡែក សកម្មភាពទីផ្សារ ចរាចរទំនិញបានប្រព្រឹត្តទៅល្អប្រសើរ និងបានសម្របសម្រួលការ តាំងពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅខេត្ត។
- មកទល់បច្ចុប្បន្ន ស្ថិតិក្រុមហ៊ុនសហគ្រាសដែលបានចុះបញ្ជីពាណិជ្ជកម្ម សរុប ចំនួន ៦៧០ច្បាប់ ក្នុងនោះក្រុមហ៊ុន ១៥០ច្បាប់ សហគ្រាស ៤៨៥ច្បាប់ និងសាខាក្រុមហ៊ុន ៣៥ច្បាប់។ ការចេញ លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មអនុវត្ត នៅប្រកចេញចូលតែមួយ ក្រុងសៀមរាប ស្រុកពួក និងស្រុកជីក្រែង សរុបមាន ចំនួន ៦១៥ច្បាប់ ក្នុងនោះអាជីវកម្មថ្មី ចំនួន ២៥៦ច្បាប់។ ចំពោះការគ្រប់គ្រងទីផ្សារ ខេត្តបានជំរុញការងារអភិវឌ្ឍន៍ផលិតផល និងទីផ្សារ ដោយ ភ្ជាប់ផលិតផលរបស់ក្រុមកសិករមកទីផ្សារតាមរយៈគម្រោង ជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) ដែលអាចនាំផលិតផលកសិកម្មមកលក់នៅផ្សារ និងទៅតាមតម្រូវការទីផ្សារដទៃទៀត។

## ៤- ការងារទំនាក់ទំនងសាធារណៈ និង កិច្ចសហប្រតិបត្តិការអន្តរជាតិ

រដ្ឋបាលខេត្តសៀមរាបបានយកចិត្តទុកដាក់ក្នុងការភ្ជាប់ទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាព ជាមួយនឹងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងល្អជាមួយបណ្តាខេត្ត-ក្រុង ជាសម្ព័ន្ធមេត្រីភាព ចំនួន ១៦ សមាគមន៍ទីភ្នាក់ងារសហប្រតិបត្តិការចំនួន ០៥ នៃប្រទេសចំនួន ០៥ ដែលសម្រេចបាននូវលទ្ធផលការងារមួយចំនួនសម្រាប់ការអភិវឌ្ឍខេត្ត រួមមាន ៖ គម្រោងបណ្តាញគ្រប់គ្រងទឹកកង្វក់ និងផលិតជីសរីរាង្គដែលមានថវិកាគាំទ្រ ១.៧លានអឺរ៉ូ គម្រោងគាំទ្របច្ចេកទេសសម្រាប់រៀបចំទីក្រុងវៃឆ្លាតខេត្តសៀមរាប ការផ្តល់អាហារូបករណ៍ និងបណ្តុះបណ្តាល

ធនធានមនុស្សដល់មន្ត្រីសិស្សនិស្សិតលើជំនាញផ្សេងៗ សរុបចំនួន ១១រូប ការកសាងផ្លូវបេតុងអភិវឌ្ឍន៍ភូមិភ្នំក្រោម ដែលមានថវិកាគាំទ្រ ៦៤ ៧៥០ដុល្លាអាមេរិក ការផ្តល់រថយន្តសំអាតផ្លូវចំនួន ០៣គ្រឿង រថយន្ត-ពន្លត់អគ្គីភ័យចំនួន ០៤គ្រឿង រថយន្តសង្គ្រោះបន្ទាន់ ០៤គ្រឿង ព្រមទាំងការផ្តល់គ្រឿងសម្ភារៈពេទ្យ និងម៉ាស់ចំនួន ២៣៨ ៥០០ម៉ាស់ ដែលបានរួមចំណែកក្នុងការទប់ស្កាត់នូវជំងឺកូវីដ-១៩ ក្នុងខេត្តសៀមរាប។ ក្រៅពីនេះរដ្ឋបាលខេត្ត ក៏ទទួលបានសមិទ្ធផលនានាតាមរយៈកិច្ចសហប្រតិបត្តិការរួមមាន៖

- គម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ ដែលអនុវត្តសកម្មភាពលើបង្កើត និងពង្រឹងស្ថាប័នក្រីក្រ ការលើកកម្ពស់ការអភិវឌ្ឍជំនាញ និងឱកាសការងារសម្រាប់ប្រជាជនក្រីក្រ ការកែលម្អសេវាមូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍សម្រាប់ប្រជាជនក្រីក្រនៅជនបទ ផ្នែកប្រព័ន្ធធារាសាស្ត្រ ផ្នែកក្រុមផលិត និង ផ្នែកក្រុមសន្សំក្នុង ៤៧ឃុំ-សង្កាត់ លើ ៩ក្រុង-ស្រុក ដែលមានគ្រួសារក្រ១ក្រ២ ទទួលផល ចំនួន ១៤ ៨៨៧គ្រួសារ ដែលមានទឹកប្រាក់ចំនួន ១៣លានដុល្លារអាមេរិក ដែលជាបដិភាគរបស់រាជរដ្ឋាភិបាល និងជំនួយពីធនាគារពិភពលោក។
- គម្រោងកាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប ជំហាន២ ខេត្តសៀមរាប ដោយអនុវត្តលើផ្នែកកសិកម្ម ផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងអរូបវ័ន្ត ដែលផ្តល់ជំនួយ និងហិរញ្ញប្បទានពីរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម(IFAD) ដែលមានទឹកប្រាក់សរុប ៦៦លានដុល្លារអាមេរិក (រាជរដ្ឋាភិបាលកម្ពុជាស្មើនឹង ៦លានដុល្លារអាមេរិក ធនាគារអភិវឌ្ឍន៍អាស៊ី ស្មើនឹង ៥០លានដុល្លារអាមេរិក និងមូលនិធិ-អន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម ស្មើនឹង ១០លានដុល្លារអាមេរិក)។
- កិច្ចសហការក្នុងការពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាត ជាមួយដៃគូអភិវឌ្ឍន៍ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង។
- បានធ្វើការសាងសង់ និងជួសជុលកំណាត់ផ្លូវស៊ីវិល្លាចាប់ពីស្តុបសុខាអង្គរហូតដល់រង្វង់នាគបាញ់ទឹកប្រវែង ១៣០០ម៉ែត្រ និង ពីក្រវាត់ក្រុងដល់ស្ថានីយ៍បូមទឹកវត្តចកប្រវែង ៧០០ម៉ែត្រឱ្យស្របតាមប្លង់បច្ចេកទេសដែលបានគ្រោងទុក ក្រោយពីការកែសម្រួលប្រព័ន្ធលូក្រោមដីរួចមក ដែលជាឥណទានធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
- រដ្ឋបាលខេត្តធ្វើការកែលម្អផ្លូវជាតិលេខ៦ ចាប់ពីស្តុបសុខាអង្គរហូតដល់រង្វង់មូលជ័យវរ្ម័នទី៧ ក្រោមជំនួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រវែង ៥,៨គីឡូម៉ែត្រ។

**៥- ការងារច្រកចេញចូលតែមួយ និង ការិយាល័យប្រជាពលរដ្ឋ**

- រដ្ឋបាលខេត្តបានទទួលសំណើសុំសេវាសរុប ចំនួន ១៥ ២១៥សេវា និងសេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់សរុបចំនួន ៦ ៩៧២សេវា ដែលសរុបជាទឹកប្រាក់ចំនួនប្រមាណជាង ៥ ៨០៣លានរៀល លើវិស័យជំនាញ ចំនួន ១៤ បន្ថែមលើសេវារដ្ឋបាលដែលផ្តល់ដោយរដ្ឋបាលខេត្ត។
- រដ្ឋបាលក្រុងស្រុកទាំង១២ មានក្រុង-ស្រុក ចំនួន ០៧ ហើយដែលមានការិយាល័យច្រកចេញចូល-តែមួយគឺ ក្រុងសៀមរាប ស្រុកជីក្រែង ស្រុកប្រាសាទបាគង ស្រុកក្រឡាញ់ ស្រុកពួក ស្រុកសូទ្រនិគម និងស្រុកបន្ទាយស្រី។ ដោយឡែកស្រុកដែលមិនទាន់បង្កើត ត្រូវប្រើប្រាស់យន្តការច្រកចេញចូលតែមួយដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋផងដែរ។
- ការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលខេត្ត បានរៀបចំតម្លើងប្រអប់សំបុត្រសម្រាប់បញ្ចេញមតិ និងបណ្តឹងតវ៉ា បានចំនួន ០៧កន្លែង នៅមុខសាលាខេត្ត មណ្ឌលរដ្ឋបាលមន្ទីរ និងតាមទីប្រជុំជននានា ព្រមទាំងបានសម្របសម្រួល ដោះស្រាយ និងបញ្ជូនទៅសមត្ថកិច្ចជំនាញនូវបណ្តឹង ឬការតវ៉ានានា បានសរុបចំនួន ៣៨បណ្តឹង និងបានដោះស្រាយរួចជាស្ថាពរសរុបចំនួន ២៩បណ្តឹង។ ដោយឡែកការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង-ស្រុកបានទទួលពាក្យបណ្តឹង ១៩៣បណ្តឹង និង បានដោះស្រាយឆ្លើយតបនឹងម្ចាស់បណ្តឹងផងដែរ។

**៦- ហេដ្ឋារចនាសម្ព័ន្ធ និងទីក្រុងឆ្លាតវៃ**

- ទោះបីពេលនេះប្រទេសជាតិយើងកំពុងប្រឈមនឹងជំងឺកូវីដ-១៩ កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០ ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា បានប្រកាសផ្តល់កញ្ចប់ថវិកា ១៥០លានដុល្លារអាមេរិក សម្រាប់អភិវឌ្ឍន៍កសាងផ្លូវ ៣៨ខ្សែ មានប្រវែង ១០៨,៧៤គីឡូម៉ែត្រ និងសាងសង់ប្រព័ន្ធលូទឹកកង្វក់ និង លូទឹកភ្លៀង ចំនួន ៤២ខ្សែ ប្រវែង ៣៣,៦៤គីឡូម៉ែត្រ ដើម្បីស្តារកែលម្អស្ទឹងសៀមរាប និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងរយៈពេល ១៣ខែ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប ក្នុងការលើកកម្ពស់សោភ័ណ្ឌភាពក្រុងសៀមរាបឱ្យក្លាយជាទីក្រុងឆ្លាតវៃក្នុងពេលអនាគត ក៏ដូចជាការទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិ ក្នុងការលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញដល់កំណើនសេដ្ឋកិច្ចជាតិនៅក្រោយជំងឺកូវីដ-១៩ គិតត្រឹមថ្ងៃនេះសាងសង់បានប្រមាណ ២០ភាគរយ។
- ជាមួយនឹងការអភិវឌ្ឍផ្លូវ និង ស្តារស្ទឹងសៀមរាប ក្នុងនោះរដ្ឋបាលខេត្តបានរៀបចំបង្កើតក្រុម-ការងារ ចំនួន ៦ក្រុម ដើម្បីចុះវាស់វែង និងសម្របសម្រួលការរុះរើសំណង់ ដែលសាងសង់លើផ្លូវ ឬដីចំណីផ្លូវ ដែលប្រជាពលរដ្ឋរស់នៅមានចំនួន ៤៣១គ្រួសារ និងបានស្ម័គ្រចិត្តធ្វើការរុះរើចំនួន ៣៧៩គ្រួសារ ទៅនៅទីតាំងថ្មី ក្នុងភូមិតានី រុនតាឯក ឃុំរុនតាឯក ស្រុកបន្ទាយស្រី ហើយរដ្ឋបាលខេត្តក៏បានរៀបចំហេដ្ឋារចនាសម្ព័ន្ធ អគ្គិសនី និងអណ្តូងទឹក ព្រមទាំងបានចាត់កម្លាំងស្រុក និងសហភាព

សម្ព័ន្ធយុវជនកម្ពុជាខេត្តសៀមរាបសហការចុះជួយរៀបចំសាងសង់លំនៅឋាន និងរោងស្នាក់នៅបណ្ដោះអាសន្នជូនប្រជាពលរដ្ឋ។

- រដ្ឋបាលខេត្តបានប្រើប្រាស់ថវិកាខេត្តក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ចំនួន ២៨ខ្សែ ដែលមានប្រវែងសរុបចំនួន ១៨ ៩១៥ម៉ែត្រ ក្នុងនោះផ្លូវបេតុង ១៧ខ្សែ ប្រវែង ១១ ២៥០ម៉ែត្រ កៅស៊ូបេតុង (AC) ០៦ខ្សែ ប្រវែង ៦ ៥៣៥ម៉ែត្រ និង DBST ០១ខ្សែ ប្រវែង ១ ១៣០ម៉ែត្រ និងបានដាក់លូ និងលូប្រអប់តាមបណ្ដោយផ្លូវ។ មកទល់ពេលនេះ ផ្លូវទាំង ២៨ខ្សែនេះ បានដំណើរការសាងសង់ និង ជួសជុល ក្នុងនោះ ១២គម្រោង បានរួចរាល់ ១០០ភាគរយ សាងសង់បាន ៥០ភាគរយឡើង បាន ០៩គម្រោង និងក្រោម ៥០ភាគរយ ចំនួន ០៣គម្រោង និងមិនទាន់អនុវត្តចំនួន ០៤គម្រោង។
- រដ្ឋបាលខេត្តបាននឹងកំពុងសិក្សាជាមួយធនាគារពិភពលោក ក្នុងការគ្រប់គ្រងទីលានចាក់សំរាម និងការកែច្នៃឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។
- ខេត្តសៀមរាប ត្រូវបានដាក់បញ្ចូលជាទីក្រុងឆ្លាតវៃអាស៊ាន ជាមួយនឹងរាជធានីភ្នំពេញ និង ខេត្ត-បាត់ដំបង។ បច្ចុប្បន្ន រដ្ឋបាលខេត្ត កំពុងសហការជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA) ដោយបានសិក្សាលើក្រុងសៀមរាបដើម្បីក្លាយជាទីក្រុងឆ្លាតវៃ ដែលផ្ដោតទៅលើវិស័យ ០៥ ក្នុងនោះ ១-វិស័យទេសចរណ៍ ២-វិស័យការដឹកជញ្ជូនចល័ត ៣-វិស័យបរិស្ថានផ្ដោតលើសំណល់រឹង និងសំណល់រាវ ៤-វិស័យសន្តិសុខ និង៥-ការគ្រប់គ្រងទិន្នន័យ។ ការអនុវត្តនូវគម្រោងនេះ នឹងអនុវត្តស្របជាមួយគម្រោងសាងសង់ផ្លូវទាំង៣៨ខ្សែ ដោយបំពាក់ភ្លើងបំភ្លឺសាធារណៈជាប្រភេទ LED ភ្លើងសញ្ញាចរាចរណ៍ឆ្លាតវៃ និងគ្រោងបំពាក់កាមេរ៉ាសុវត្ថិភាព តាមបណ្ដាផ្លូវទាំង ៣៨ខ្សែផងដែរ។ កន្លងមក ខេត្តបានសហការក្រុមហ៊ុន វីសាន់ នៃសាធារណរដ្ឋប្រជាមានិតចិន និងក្រុមមីនីបៀរ របស់ប្រទេសជប៉ុន ដោយបំពាក់ភ្លើងបំភ្លឺសាធារណៈតាមដងផ្លូវចំនួន ៥១៤៦អំពូល។

## ៧- ការងារអគ្គិសនី និង ទឹកស្អាត

- ការងារផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្ត បានចែកចាយទូទាំងឃុំ សង្កាត់ ១០០ឃុំ-សង្កាត់ របស់ខេត្ត ដែលអាចផ្គត់ផ្គង់បានអតិថិជនសរុប ១៩៨ ១៩៤អតិថិជន ស្មើនឹង ៨៩០ភូមិ នៃភូមិសរុប ៩១០ភូមិ នៅសល់ ២០ភូមិ ដែលពន្លឿនតភ្ជាប់បណ្ដាញឱ្យបានឆាប់រហ័ស។
- ការផលិតទឹកស្អាតសម្រាប់ផ្គត់ផ្គង់ក្នុងក្រុងបាន ៤លានម៉ែត្រគូប ស្មើនឹង ៦៨% នៃផែនការ និងការតបណ្ដាញថ្មីជូនអតិថិជនចំនួន ១ ៧១៣បណ្ដាញ ដែលមានអតិថិជនសរុប ១២ ៦៩៥អតិថិជន។ យើងបានបញ្ចប់ទាំងស្រុងនូវការអនុវត្តគម្រោងបណ្ដាញទឹកស្អាត ដែលជាថវិកាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានប្រវែងសរុប ១០០គីឡូម៉ែត្រ និងបានភ្ជាប់បណ្ដាញចូលផ្ទះចំនួន ៥ ០០០តំណ។ មកទល់ពេលនេះ ការផលិតទឹកសម្រាប់ផ្គត់ផ្គង់ក្នុងក្រុងបានចំនួន ៣០ ០០០ម៉ែត្រ

គូបក្នុងមួយថ្ងៃ ដែលមិនទាន់ឆ្លើយតបនឹងតម្រូវការនៅឡើយ ដើម្បីបំពេញតម្រូវការ បច្ចុប្បន្នយើងកំពុងបន្តអនុវត្តគម្រោងសាងសង់រោងចក្រដែលមានសមត្ថភាពអាចផលិត ៦០ ០០០ម៉ែត្រគូប ក្នុងមួយថ្ងៃ ព្រមទាំងដាក់បណ្តាញមេ និងបណ្តាញចែកចាយប្រវែង ១៦៦គីឡូម៉ែត្រ បាននឹងកំពុងអនុវត្តកិច្ចសន្យាសាងសង់ ដែលជាថវិកាកម្ចីពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) បានអនុវត្តបាន ១៧% ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២២។ ដោយឡែក ប្រជាពលរដ្ឋនៅតាមតំបន់ជនបទបានប្រើប្រាស់ទឹកលើដី និង ក្រោមដីសម្រាប់បំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃ ជាមួយគ្នានេះ នៅក្នុងស្រុក ចំនួន ០៥ ដែលមានការវិនិយោគ ផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រជាពលរដ្ឋបានចំនួន ៩ ៣៩៦គ្រួសារ ស្មើនឹងជាង ១លានម៉ែត្រគូប។

## ៨- ការងារដីធ្លី និងសំណង់

- ក្នុងស្ថានភាពប្រជាពលរដ្ឋជួបវិបត្តិសេដ្ឋកិច្ចក្នុងអំឡុងកូវីដ-១៩ក៏ដោយ វិស័យដីធ្លី និងសំណង់ក្នុងខេត្តសៀមរាប ក៏នៅមានភាពរីកចម្រើនលើវិស័យសំណង់ បានចេញលិខិតអនុញ្ញាតសាងសង់ចំនួន ១៤៦ច្បាប់។ ក្រុមការងារបានចុះត្រួតពិនិត្យ និងទប់ស្កាត់សំណង់ ចំនួន ១១លើក ស្មើនឹង ១១ការដ្ឋាន ផ្អាកការដ្ឋានសាងសង់ ចំនួន ០៤ការដ្ឋាន និងអនុញ្ញាតបន្តសាងសាង់ ០២ច្បាប់។
- បានចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដោយបញ្ចូលទិន្នន័យក្បាលដីបាន ចំនួន ២០ ៥៩២ក្បាលដី និងបានចែកប័ណ្ណជូនប្រជាពលរដ្ឋ ៦ ៧៦៤ប័ណ្ណ ដោយប្រើប្រាស់ប័ណ្ណដីដែលមាន QR CODE។ ការចុះបញ្ជីដីដាច់ដោយដុំបាន ចំនួន ៨៤ក្បាលដី និងចុះបញ្ជីផ្ទេរកម្មសិទ្ធិបាន ចំនួន ៣ ០៦៧ក្បាលដី។
- រដ្ឋបាលខេត្តបានកំពុងរៀបចំចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធបន្តនៅក្រុងសៀមរាប និងតាមបណ្តាឃុំ ទីរួមស្រុក ចំនួន ០៦ នៅតាមបណ្តោយផ្លូវជាតិ៦។
- បានសម្របសម្រួលដោះស្រាយវិវាទដីធ្លីនៅតាមក្រុង ស្រុក ទាំង១២ និងបន្តសម្របសម្រួលដោះស្រាយជាបន្តបន្ទាប់ស្របតាមនីតិវិធី និងច្បាប់ជាធរមាន។

## ៩- ការងារបរិស្ថាន

- អនុវត្តតាមអនុសាសន៍របស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី រដ្ឋបាលខេត្តបានបង្កើតក្រុមការងារតាមដាន និងទប់ស្កាត់ការរុករានទន្ទ្រានដីរដ្ឋគ្រប់ប្រភេទ និងផ្សព្វផ្សាយជូនរដ្ឋបាលក្រុង ស្រុក ដោយចាត់តាំងអភិបាលរងខេត្តដឹកនាំក្រុមការងារអនុវត្តតាមក្រុង ស្រុកដោយមានការចូលរួមពីមន្ទីរ-អង្គភាពនានា កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទចុះពិនិត្យ ពិភាក្សា និងធ្វើបច្ចុប្បន្នភាពលើការទប់ស្កាត់ការរុករានទន្ទ្រានដីរដ្ឋគ្រប់ប្រភេទ ដើម្បីរឹបអូសយកដីធ្វើជាកម្មសិទ្ធិនៅតាមបណ្តាក្រុង-ស្រុក។
- ពាក់ព័ន្ធនឹងគម្របព្រៃឈើ២០០២ និងតំបន់ការពារ ក្រុមការងារបាននឹងកំពុងដំណើរការនីតិវិធីរបស់ខ្លួន ដើម្បីធ្វើការកាត់ឆ្វៀលជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ដាំដុះដាក់ស្តែង ក្រៅពីនេះអាជ្ញាធរនឹងរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ។

## ១០- ការងារអប់រំ

- ទូទាំងខេត្តមានគ្រឹះស្ថានសិក្សាសរុបចំនួន ១ ០៧៧សាលា(កើន ១០សាលា) ត្រូវជា ៧ ០៦៦ថ្នាក់ សិស្សសរុប ២៨៥ ០៥៧នាក់ ស្រី ១៤៤ ៧០៧នាក់ ក្នុងនោះមត្តេយ្យសិក្សារដ្ឋមាន ៤៤៧សាលា ត្រូវជា ៩១៥ថ្នាក់ កុមារសរុប ៤០ ៤៦៣នាក់ ស្រី ២១ ០០៣នាក់ បឋមសិក្សា ៥០៧សាលា ត្រូវជា ៤ ៥៨៩ថ្នាក់ សិស្សសរុប ១៦៦ ៣៨១នាក់ ស្រី ៨០ ៣៥១នាក់ គ្រឹះស្ថានមធ្យមសិក្សាមាន ១២៣សាលា ក្នុងនោះវិទ្យាល័យ ៤១សាលា ត្រូវជា ១ ០៤៧ថ្នាក់ មានសិស្សសរុប ៥៣ ៤៧៩នាក់ ស្រី ២៩ ៩៤៦នាក់ អនុវិទ្យាល័យចំនួន ៨២ សាលា ត្រូវជា ៥១៥ថ្នាក់ សិស្សសរុប ២៤ ៧៣៤នាក់ ស្រី ១៣ ៤០៧នាក់។ យុវជនកាយរិទ្ធិ សរុប ទូទាំង ខេត្តចំនួន ៨ ៧៦១នាក់(កើន ៦១៧នាក់) ស្រី ៤ ៥២៦នាក់ កាកបាទក្រហមសរុបចំនួន ២ ២៨១ នាក់(កើន ៦០៦នាក់) ស្រី ១ ៣៣៥នាក់ សមាជិកក្រុមប្រឹក្សា-កុមារ ១២៦ ៥០៩នាក់ ស្រី ៦៥ ១៣៩ នាក់ ក្រុមប្រឹក្សាយុវជន ២៥ ៩៣៩នាក់ ស្រី ១២ ៦១៨នាក់។ មន្ទីរអប់រំ យុជន និងកីឡាខេត្តបានរៀបចំ ឱ្យមាន ការ ប្រកួតកីឡាតាមក្រុង/ស្រុកចំនួន ៥លើក និង រៀបចំការប្រកួតកីឡាសិស្សបឋមសិក្សា ជ្រើសរើសជើងឯកថ្នាក់ខេត្ត ប្រចាំឆ្នាំសិក្សា២០១៩-២០២០ ចំនួន ១លើក នៅកីឡដ្ឋានខេត្តសៀមរាប។

## ១១- ការងារសុខាភិបាល និង វិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩

- ដើម្បីរួមចំណែកក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋបាលខេត្តបានបញ្ជូនថ្នាក់ដឹកនាំ ខេត្ត មន្ត្រី និងមន្ទីរ-អង្គភាពប្រចាំការនៅព្រំប្រទល់កម្ពុជា-ថៃ (ច្រកអន្តរជាតិដូង ខេត្តបាត់ដំបង ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ) ដើម្បីសម្របសម្រួលក្នុង ការដឹកជញ្ជូនប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីក្រៅប្រទេស(ប្រទេសថៃ) ដោយគិតចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ មានចំនួន ២០ ១៥០នាក់ ស្រី ៨ ៨៧៦នាក់។ បងប្អូនប្រជាពលរដ្ឋមកពីក្រៅប្រទេសទាំងអស់ត្រូវបានពិនិត្យសុខភាព និងបន្តណែនាំឱ្យធ្វើ ចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅតាមមណ្ឌលដែលអាជ្ញាធរពាក់ព័ន្ធបានរៀបចំ។
- ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីបាន ផ្តល់ម៉ាស់ ចំនួន ១លានម៉ាស់ ដល់រដ្ឋបាលខេត្តសៀមរាប ដើម្បីធ្វើការចែកជូនបងប្អូនប្រជាពលរដ្ឋ និងថវិកាចំនួន ៨០លានរៀល សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋក្រីក្រក្នុងអំឡុងពេលធ្វើចត្តាឡីស័ក្ក។
- ស្របជាមួយគ្នានេះ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់របស់រដ្ឋបាលខេត្តសៀមរាប បានចូលរួមបរិច្ចាគ ប្រាក់បៀវត្សផ្ទាល់ខ្លួន ជូនគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងរាជរដ្ឋាភិបាល សរុបមានចំនួន ៥២១រូប ដែលមានទឹកប្រាក់សរុបជាង ១០៧លានរៀល និងបរិច្ចាគថវិកា សម្រាប់ទិញវ៉ាក់សាំងកូវីដ-១៩ ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ ៦៣លានរៀល និងជា ប្រាក់ដុល្លារអាមេរិក ចំនួន ៣២ ១៩១ដុល្លារអាមេរិក។

**១២- ឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ជនងាយរងគ្រោះ**

- ជាមួយនឹងការប្រឈមនៃស្ថានភាពការរីករាលដាលជំងឺកូវីដ-១៩ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចំនួន ៤៤ ៨៦៨គ្រួសារ ស្មើនឹងថវិកាចំនួនប្រមាណ ៨,៥៣ពាន់លានរៀល និងឧបត្ថម្ភសាច់ប្រាក់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ចំនួន ២៦ ១៤២នាក់ ស្មើនឹងទឹកប្រាក់ប្រមាណ ១,៣៣ពាន់លានរៀល។

ក្រៅពីសមិទ្ធផលដូចបានជម្រាបជូនខាងលើ រដ្ឋបាលខេត្ត ដែលមានក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ព្រមទាំងការគាំទ្រយ៉ាងយកចិត្តទុកដាក់ខ្ពស់របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តសៀមរាប ដែលដឹកនាំដោយសម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានធ្វើឱ្យខេត្តសៀមរាបដោះស្រាយបាននូវបញ្ហាប្រឈម ការលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

រដ្ឋបាលខេត្តបានដាក់ចេញនូវគោលនយោបាយផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងទិសដៅសកម្មភាព ជាអាទិភាពដើម្បីចូលរួមចំណែកក្នុងការអនុវត្ត និងសម្រេចបាននូវគោលនយោបាយ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខដឹកនាំប្រកបដោយគតិបណ្ឌិត។ បន្ថែមលើនេះ រដ្ឋបាលខេត្ត ប្តេជ្ញាបន្តពង្រឹងប្រសិទ្ធភាពការដឹកនាំដើម្បីបន្តចូលរួមចំណែកដ៏ធំធេង ក្នុងការរក្សាបាននូវសន្តិសុខស្ថេរភាពនយោបាយ និងសង្គម និងបង្កើនគុណភាពនៃការផ្តល់សេវាប្រកបដោយគណនេយ្យភាព តម្លាភាព មានការអភិវឌ្ឍ ប្រកបដោយចីរភាព បង្កើតបាននូវបុរេលក្ខខណ្ឌចាំបាច់ និងបរិស្ថានអនុគ្រោះសម្រាប់ការប្រែក្លាយខ្លួនឲ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

## IV- ទិសដៅបន្ត

ឆ្នាំ២០២១ រដ្ឋបាលខេត្ត មន្ទីរ អង្គភាពជុំវិញខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវមានឆន្ទៈប្តេជ្ញាខ្ពស់ចំពោះបេសកកម្មរបស់ខ្លួន ដើម្បីបន្តអនុវត្តភារកិច្ចការងារដែលនៅសេសសល់ពីឆ្នាំ២០២០ផង និងកិច្ចការនានាក្នុងឆ្នាំ២០២១ ដែលស្ថិតក្នុងក្របខណ្ឌ នៃផែនការអភិវឌ្ឍខេត្ត ដើម្បីសម្រេចបាននូវសមិទ្ធផលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងអនុវត្តតាមអភិក្រមទាំង៥ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទៅលើភាពអសកម្មនានា។

ពិតណាស់ទិសដៅការងារឆ្នាំ២០២១ រដ្ឋបាលខេត្តបានធ្វើការប៉ាន់ប្រមាណប្រកបដោយចក្ខុវិស័យទូលំទូលាយ ក្នុងការកំណត់នូវយុទ្ធសាស្ត្រក្នុងដំណាក់កាលនីមួយៗ និងស្របតាមសភាពការណ៍ជាក់ស្តែង នៃការវិវត្តនូវស្ថានភាពសង្គមសេដ្ឋកិច្ច ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋនិងរក្សាបាននូវស្ថេរភាព

សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថានធម្មជាតិ វប្បធម៌ សីលធម៌សង្គម សេចក្តីថ្លៃថ្នូរ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ផ្តើមចេញពីកត្តាគន្លឹះទាំងនេះ រដ្ឋបាលខេត្តសៀមរាប បានដាក់ចេញនូវទិសដៅ និង វិធានការចាំបាច់ចម្បងៗ សម្រាប់អនុវត្តក្នុងឆ្នាំ២០២១ ដែលខ្ញុំសូមលើកឡើងនូវការងារអាទិភាពមួយចំនួន ដូចខាងក្រោមនេះ ៖

១- បន្តពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ផ្សព្វផ្សាយលក្ខណៈសម្បត្តិ ០៩យ៉ាងនៃភូមិ ឃុំ មានសុវត្ថិភាព ជំរុញចលនាប្រជាជនចូលរួម និងកសាងកម្លាំងប្រជាការពារ សាងសង់ប៉ុស្តិ៍ប្រជាការពារ សម្រាប់ចូលរួមសហប្រតិបត្តិការបង្រ្កាបបទល្មើសគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ។

២- គ្រប់មន្ទីរ អង្គភាពត្រូវរួមសហការឱ្យបានកាន់តែសកម្ម និងមានប្រសិទ្ធភាព និងចាត់វិធានការបើកកិច្ចប្រតិបត្តិការបង្ការ បង្រ្កាបបទល្មើសគ្រប់ប្រភេទរួមមាន បទល្មើសផ្លូវភេទ ការជួញដូរស្ត្រី និងកុមារ គ្រឿងញៀន ល្បែងស៊ីសង បទល្មើសបច្ចេកវិទ្យា បទល្មើសសេដ្ឋកិច្ច ពិសេសផលិតផលក្លែងក្លាយមានសារធាតុគីមីហាមឃាត់គ្រប់ប្រភេទ និងឱសថក្លែងក្លាយ។

៣- ពង្រីកសក្តានុពលទេសចរណ៍ ដោយពង្រីកតំបន់ទេសចរណ៍ធម្មជាតិ និងតំបន់កែច្នៃ ក្រៅពីប្រាសាទ និងសេវាកម្មទេសចរណ៍ អភិវឌ្ឍធនធានមនុស្សផ្នែកជំនាញវិជ្ជាជីវៈទេសចរណ៍លើការងារបដិសណ្ឋារកិច្ច សេវាកកម្មដឹកជញ្ជូន និងសេវាមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងរៀបចំផែនការអភិវឌ្ឍទេសចណ៍ទៅតាមតំបន់គោលដៅទេសចរណ៍ក្នុងក្រុង និងតាមបណ្តាស្រុក។ ជាមួយគ្នានោះខេត្តនឹងអនុវត្តសកម្មភាពនានាឆ្លើយតបទៅនឹងស្ថានភាព នៃការធ្លាក់ចុះភ្ញៀវទេសចរស្របតាមវិធានការនានារបស់រាជរដ្ឋាភិបាល ការស្តារហេដ្ឋារចនាផ្លូវថ្នល់ និង ការកែលម្អសោភ័ណ្ឌភាពក្នុងក្រុងប្រកបដោយភាពទាក់ទាញ និង ទីក្រុងឆ្លាតវៃ។

៤- បន្តជំរុញការដាំដុះ ផ្សព្វផ្សាយបច្ចេកទេសកសិកម្មទំនើប បង្កើនផលិតផលកសិកម្មតាមកិច្ចសន្យាពង្រីកឱ្យមានផលិតផលសុវត្ថិភាពនៅលើទីផ្សារ ការចិញ្ចឹមសត្វ វារីវប្បកម្ម រៀបចំពិព័រណ៍ផលិតផលគាំទ្រការកែច្នៃ វេចខ្ចប់ និងទីផ្សារ ក្នុងន័យបង្កើត ប្រាក់ចំណូលគ្រួសារ កាត់បន្ថយចំណាកស្រុក ការនាំចូល និងបំពេញតម្រូវការក្នុងស្រុក និងការនាំចេញ។

៥- គណៈកម្មាការជាតិជំរុញចលនាភូមិមួយផលិតផលមួយ និងចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយដើម្បីផ្តល់នូវនិមិត្តសញ្ញាភូមិមួយផលិតផលមួយក្នុងការជ្រើសរើសផលិតផល ដែលមានសក្តានុពល និងល្អបំផុតប្រចាំខេត្ត។

៦- ពន្លឿនការចុះបញ្ជីដីលក្ខណៈជាប្រព័ន្ធតាមក្រុង ស្រុក ដើម្បីផ្តល់ប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋឱ្យបានចប់តាមផែនការឆ្នាំ២០២១។

៧- ស្នើសុំការគាំទ្របច្ចេកទេសក្នុងការរៀបចំប្លង់គោលដីធ្លីស្រុកតាមបណ្តោយផ្លូវជាតិលេខ៦។ ដោយឡែកស្រុកដទៃទៀត ត្រូវយកចិត្តទុកដាក់រៀបចំទីប្រជុំជនស្រុក ឃុំ ឱ្យមានរបៀបរៀបរយ និងប្រកបទៅដោយទស្សនៈវិស័យទីប្រជុំជន។

៨- អប់រំ ផ្សព្វផ្សាយ ពង្រឹងការទប់ស្កាត់ និងចាត់វិធានការតាមផ្លូវច្បាប់ចំពោះការបំផ្លាញធនធានធម្មជាតិ និងទន្ទ្រានកាន់កាប់ដីព្រៃឈើក្នុងតំបន់ការពារធម្មជាតិ ព្រៃសហគមន៍ ដែនអភិរក្ស និងរបៀងជីវៈចម្រុះ លើកផែនការការងារសម្រាប់ការបោះបង្គោលព្រំប្រទល់ និងលើកស្លាកសញ្ញាហាមឃាត់ ឬសម្គាល់តំបន់ទាំងនោះ។

៩- ពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក លើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងគ្រប់គ្រងប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ បន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនក្នុងការគ្រប់គ្រងសំរាម។

១០- ពង្រឹងការផ្តល់សេវារដ្ឋបាលតាមរយៈច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត ក្រុង ស្រុក ឱ្យបានឆាប់រហ័ស ធានាបានតម្លាភាព និងដោះស្រាយ ឬលើកសំណូមពរដោះស្រាយចំពោះ សេវាមានលក្ខណៈស្មុគស្មាញ។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ និងសូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសន្និសីទទាំងមូល សមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ**!